# ព្រះវិហារវត្តភ្នំ

## ការអភិរក្ស និង អភិវឌ្ឍ



សាលារាជធានីភ្នំពេញ

ឆ្នាំ ២០១១

# ព្រះវិហារវត្តភ្នំ

## ការអភិរក្ស និង អភិវឌ្ឍ



www.phnompenh.gov.kh



# អារម្ភកថា

រាជធានីភ្នំពេញ គឺជាមជ្ឈមណ្ឌលប្រមូលផ្តុំលើវិស័យសេដ្ឋកិច្ច សង្គមកិច្ច នយោបាយ វប្បធម៌ រដ្ឋបាល និងការទូតរបស់ព្រះរាជាណាចក្រកម្ពុជា។ រំលឹកពីប្រវត្តិកាលរាជធានីភ្នំពេញ យើងតែងដឹងគុណជានិច្ចដល់ បុព្វការីជន ដែលបានធ្វើពលីកម្មដ៏ធំធេង ក្នុងការកសាងនូវសមិទ្ធផលនានា និងកេរដំណែលវប្បធម៌ជាច្រើន បន្សល់ទុកមកដល់បច្ចុប្បន្ន ដែលធ្វើឱ្យភ្នំពេញជាទីក្រុងស្រស់ឆើតឆាយមួយ សក្តិសមទទួលបានងារថាជា **«ទីក្រុងគុជនៅអាស៊ី»**។

រាជធានីភ្នំពេញ បានពុះពារជំនះការលំបាកគ្រប់បែបយ៉ាង ក្នុងការស្តារឡើងវិញចេញពីការខូចខាតខ្ទេចខ្ទាំ ដែលរបបប្រល័យពូជសាសន៍ប៉ុលពតបានបំផ្លិចបំផ្លាញ។ ក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ ភ្នំពេញមានការអភិវឌ្ឍយ៉ាងខ្លាំងក្លា ទាំងហេដ្ឋារចនាសម្ព័ន្ធ បរិស្ថាន និងវប្បធម៌ ក្រោមទិសស្លោក «ភ្នំពេញក្នុងមុំសន្តិភាព សុវត្ថិភាព សោភ័ណភាព និងវឌ្ឍនភាព» ដើម្បីសុខុមាលភាពប្រជាជន និងរួមចំណែកលើកស្ទួយកិត្យានុភាពកម្ពុជាលើឆាកអន្តរជាតិ ក្រោមការដឹកនាំដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជាប្រមុខ ។

ប្រវត្តិទាក់ទងនឹងភ្នំពេញមានយូរលង់ណាស់មកហើយ ដ្បិតនៅជុំវិញតំបន់នេះមានបន្សល់ស្លាកស្នាមទីទួលបុរាណ និងសំណល់ប្រាសាទតាំងពីសម័យមុនអង្គរ និងសម័យអង្គរមកម្លេះ។ តឹកតាងប្រវត្តិសាស្ត្រដ៏សំខាន់មួយរបស់ភ្នំពេញគឺទីតាំង **«ភ្នំដូនពេញ»** សព្វថ្ងៃហៅថា **«វត្តភ្នំ»** ដែលផ្តួចផ្តើមកសាងដោយ **ដូនពេញ** នៅគ.ស.១៣៧២ សម្រាប់តម្កល់ព្រះពុទ្ធរូបបួនអង្គ និងបដិមាថ្មមួយអង្គ ដែលបានរកឃើញនៅក្នុងប្រហោងដើមគគីរធំមួយអណ្តែតរសាត់តាមទឹកទន្លេ។ ក្រោយមក នៅគ.ស.១៤៣៤ **ព្រះបាទពញាយ៉ាត** បានផ្លាស់ព្រះរាជវាំងពីទួលបាសាណ មកតាំងរាជធានីនៅទិសអាគ្នេយ៍នៃភ្នំដូនពេញ នាត្រើយខាងលិចទន្លេចតុមុខ។ ដូច្នេះហើយ វត្តភ្នំ គឺជាបេតិកភណ្ឌដ៏ចំណាស់ ដែលផ្សារភ្ជាប់យ៉ាងជិតស្និទ្ធជាមួយប្រវត្តិនៃការកកើតភ្នំពេញ ហើយបច្ចុប្បន្ន ក្លាយជាបូជនីយដ្ឋានប្រវត្តិសាស្ត្រផង

www.phnompenh.gov.kh

ជាមណ្ឌលពុទ្ធសាសនាផង និងជារមណីយដ្ឋានទេសចរណ៍ដ៏ទាក់ទាញមួយនៅរាជធានីភ្នំពេញ។

នៅដើមឆ្នាំ២០១១នេះ ដោយទទួលបានគោលការណ៍ពីរាជរដ្ឋាភិបាល សាលារាជធានីភ្នំពេញ បានធ្វើការជួសជុលកែលម្អព្រះវិហារវត្តភ្នំ ដែលមានសភាពចាស់ទ្រុឌទ្រោមណាស់ទៅហើយ ដើម្បីអភិរក្សសំណង់បេតិកភណ្ឌប្រវត្តិសាស្ត្រនេះឲ្យបានគង់វង្សយូរអង្វែង ក្នុងគោលបំណងថែរក្សាកេរដំណែលដូនតាផង និងដើម្បីរំលឹកដល់គុណូបការៈដ៏ថ្លៃថ្លារបស់បុព្វការីជនទាំងអស់ដែលជាស្ថាបនិកវត្តភ្នំ និងរាជធានីភ្នំពេញផង។ មិនតែប៉ុណ្ណោះ វត្តភ្នំ កាន់តែមានភាពស្រស់បំព្រងថែមទៀតទាក់ទាញភ្ញៀវទេសចរជាតិ និងអន្តរជាតិ និងជាទីសក្ការៈបូជារបស់ប្រជាជនខ្មែរ ដោយឈរយ៉ាងរឹងមាំជាចំណុចគោល និងជានិមិត្តរូបនៃរាជធានីភ្នំពេញ។

បេតិកភណ្ឌវប្បធម៌ និងប្រវត្តិសាស្ត្រ គឺជាផ្នែកសំខាន់មួយដែលយើងទាំងអស់គ្នាត្រូវយល់ដឹងពីអតីតកាលរបស់ខ្លួន ហើយរួមគ្នាបន្តថែរក្សាកេរមត៌កវប្បធម៌ទាំងនោះឲ្យបានគង់វង្សសម្រាប់កូនចៅជំនាន់ក្រោយទៀត ដើម្បីអត្តភាពជាតិ និងភាពសំបូរបែបនៃជីវិតវប្បធម៌ សាសនា និងសកម្មភាពសង្គម ដូចដូនតាយើងពោលថា «វប្បធម៌រលត់ ជាតិរលាយ វប្បធម៌ពណ្ណរាយ ជាតិថ្កើងថ្កាន»។

មុននឹងបញ្ចប់ យើងខ្ញុំសូមសម្តែងនូវអំណរគុណដ៏ជ្រាលជ្រៅបំផុតចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត ដែលបានផ្តល់ឱកាស និងលទ្ធភាពគ្រប់បែបយ៉ាង ក្នុងការកសាង និងអភិវឌ្ឍរាជធានីភ្នំពេញរហូតតរៀងមក។

រាជធានីភ្នំពេញ,ថ្ងៃទី24ខែកក្កដា ឆ្នាំ២០១១

**អភិបាលរាជធានីភ្នំពេញ**

**កែប ជុតិមា**

www.phnompenh.gov.kh

# មាតិកា


អារម្ភកថា

១. ប្រវត្តិរាជធានីភ្នំពេញ ១

១.១. រឿងព្រេងកំណើតរាជធានីភ្នំពេញ ២

២. ភ្នំពេញក្នុងរជ្ជកាលព្រះបាទពញាយ៉ាត ៥

៣. ភ្នំពេញសម័យអាណានិគមបារាំង ៩

៤. ភ្នំពេញក្នុងសម័យសង្គមរាស្ត្រនិយម ១០

៥. ភ្នំពេញក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ប៉ុល ពត) ១១

៦. ភ្នំពេញសម័យតេជោសែន ១២

៦.១. ការងារសន្តិសុខ និងការគ្រប់គ្រងរដ្ឋបាលដែនដី ១៣

៦.២. ការងារអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ និងសេដ្ឋកិច្ច ១៥

៦.៣. វិស័យអប់រំ សុខាភិបាល សង្គមកិច្ច វប្បធម៌ និងសាសនា ១៦

៦.៤. ការងារលើកកម្ពស់គុណភាពបរិស្ថាន និងផ្គត់ផ្គង់ទឹកស្អាត ១៧

៦.៥. ការងារលើកកម្ពស់យែនឌ័រក្នុងកិច្ចអភិវឌ្ឍន៍សង្គម ១៨

៧. វត្តភ្នំ: ការអភិរក្ស និងអភិវឌ្ឍ ១៩

៧.១. ការងារជួសជុល និងកែលម្អវត្តភ្នំ ២០

ក. សកម្មភាពជួសជុល និងថែរក្សាវត្តភ្នំ ឆ្នាំ២០០១ ២២

ខ. ការងារសិក្សា និងចុះបញ្ជីចេតិយវត្តភ្នំ ៣១

៧.២. គម្រោងជួសជុល កែលម្អ ព្រះវិហារវត្តភ្នំ ឆ្នាំ២០១១ ៣៧

១. ទីតាំងភូមិសាស្ត្រព្រះវិហារវត្តភ្នំ ៣៩

២. ទិដ្ឋភាពព្រះវិហារវត្តភ្នំ ៤១

២.១. ស្ថានភាពសំណង់ព្រះវិហារវត្តភ្នំ ៤៤

ក. សំណង់គ្រឹះ ៤៤

ខ. តួព្រះវិហារ ៤៧

គ. ផ្នែកដំបូល ៤៩

២.២. ស្ថានភាពគំនូរ និងរូបចម្លាក់ ៥៣

ក. ទិដ្ឋភាពទូទៅខាងក្នុងព្រះវិហារ ៥៣

ខ. គំនូរ ៥៤


www.phnompenh.gov.kh

គ. រូបចម្លាក់ ៥៥

២.៣. ស្ថានភាព ជញ្ជាំង បង្កាន់ដៃ សសរ និងគ្រឿងបង្គុំឈើ ៥៦

២.៤. បណ្តាញអគ្គិសនី និងប្រព័ន្ធភ្លើងបំភ្លឺ ៥៦

៣. ការងារជួសជុល និងកែលម្អព្រះវិហារវត្តភ្នំ ៥៨

៣.១. ពិធីក្រុងពាលីបើកការដ្ឋានជួសជុលកែលម្អព្រះវិហារវត្តភ្នំ ៥៨

៣.២. ការងារពង្រឹង ជួសជុល កែលម្អផ្នែកសំណង់ព្រះវិហារៈ លេណគ្រឹះ ដំបូល ជញ្ជាំង ខឿន ទ្វារ និងបង្អួច ៥៩

ក. ការងារជួសជុលលេណគ្រឹះ ៥៩

ខ. ការងារជួសជុលផ្នែកដំបូល ជញ្ជាំង ទ្វារ និងបង្អួច ៦១

៣.៣. ការងារពង្រឹង ជួសជុល និងលាងសំអាតគំនូរលើៈ ជញ្ជាំង ពិតាន ទ្វារ បង្អួច និងសសរ ៧០

ក. ការថតរូបគំនូរដើម្បីចងក្រងជាឯកសារ ៧០

ខ. ការជួសជុល ពង្រឹង និងលាងសំអាតគំនូរ ៧១

គ. ការប្រៀបធៀបរូបគំនូរ មុន និងក្រោយពេលជួសជុល ៧៧

៣.៤. ការងារពង្រឹង ជួសជុល និងលាងសំអាតរូបចម្លាក់ៈ ព្រះអង្គធំ បុស្បុក និងពុទ្ធបដិមា ៨០

៣.៥. ការងាររៀបចំបណ្តាញអគ្គិសនីថ្មីៈ បំពាក់ខ្សែភ្លើង ទូបញ្ជា អំពូលភ្លើង និងដំឡើងបង្គោលភ្លើង ៨១

៣.៦. ការងារជួសជុលកែលម្អបរិវេណលើភ្នំ ដើម្បីសម្រួលដល់ការទស្សនា ៨៣

ក. ការជួសជុលកម្រាលខឿន ៨៣

ខ. ការជួសជុលជណ្តើរខាងជើងព្រះវិហារ ៨៤

គ. ការជួសជុលជើងបង្គោលភ្លើង ៨៤

៤. លទ្ធផលសម្រេចនៃគម្រោងជួសជុលកែលម្អព្រះវិហារវត្តភ្នំ ៨៥


www.phnompenh.gov.kh

# ១. ប្រវត្តិរាជធានីភ្នំពេញ

រាជធានីភ្នំពេញ ចាប់ផ្តើមស្ថាបនាឡើងដំបូងបង្អស់នៅពុទ្ធសតវត្សទី២១ ត្រូវនឹងសតវត្សទី១៥ ក្នុងរជ្ជកាលព្រះបាទពញាយ៉ាត នៅពេលដែលទ្រង់ចាកចោលក្រុងអង្គរ មកសាងព្រះរាជវាំងថ្មីនៅទួលបាសាណ ក្នុងខេត្តស្រីសឈរ ដែលសព្វថ្ងៃស្ថិតក្នុងស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ។ ប៉ុន្តែដោយសារទីតាំងនៅទួលបាសាណ ពុំសូវមានអំណោយផលសំរាប់ការតាំងទីនៃរាជធានីថ្មីបាន ព្រោះតែងមានទឹកជន់លិចនៅរដូវវស្សារាល់ឆ្នាំ ទើបមិនយូរប៉ុន្មាន នៅគ.ស.១៤៣៤ ព្រះអង្គក៏យាងចាកចេញពីទួលបាសាណ មកកសាងទីក្រុងថ្មីនៅមុំទន្លេបួនមុខ គឺទីក្រុងភ្នំពេញ រហូតមកដល់សព្វថ្ងៃនេះ ។



ការស្ថាបនារាជធានីភ្នំពេញ មាន២ ដំណាក់កាលៈ

- **ដំណាក់កាលទី១:** ក្នុងរជ្ជកាលព្រះបាទពញាយ៉ាត នាសតវត្សទី១៥ តែមិនថិតថេរ
- **ដំណាក់កាលទី២:** ក្នុងរជ្ជកាលព្រះបាទនរោត្តម នាសតវត្សទី១៩ ជារាជធានីជាក់លាក់មួយ ដែលបន្តរហូតមកដល់បច្ចុប្បន្ននេះ។

www.phnompenh.gov.kh

មូលហេតុដែលនាំឲ្យមានការកសាងរាជធានីជាពីរលើកបែបនេះ ព្រោះថាក្រោយពី **ព្រះបាទពញាយ៉ាត**ទ្រង់សោយទិវង្គតទៅ សង្គ្រាមក្នុងស្រុកតែងកើតឡើងជាហូរហែ ឯរាជធានីបានធ្វើការផ្លាស់ទីទៅច្រើនកន្លែងដូចជា ពោធិ៍សាត់ បរិបូណ៌ លង្វែក ឧត្តុង្គ ។ល។ លុះមកដល់គ.ស.១៨៦៥ ក្នុងរាជ្យ**ព្រះបាទនរោត្តម** ព្រះអង្គបានមកតាំងរាជធានីនៅភ្នំពេញវិញមកដល់សព្វថ្ងៃ ។

## ១.១ រឿងព្រេងកំណើតរាជធានីភ្នំពេញ

"ភ្នំដូនពេញ" ដែលសន្មតជានាមរបស់ទីក្រុងភ្នំពេញសព្វថ្ងៃ គឺកើតមកតាំងពីមុនពេលស្ថាបនាព្រះរាជវាំងមកម្ល៉េះ ពោលគឺមានមុនការមកដល់របស់ស្តេចពញាយ៉ាតទៅទៀត។ រឿងនិទានមួយតំណាលថា: ក្នុងកាលកន្លងទៅហើយ (គ.ស.១៣៧២) មានដូនចាស់ម្នាក់ឈ្មោះ "ពេញ" ជាអ្នកមានភោគសម្បត្តិបរិបូណ៌ មានទីលំនៅលើទីទួលខាងកើតភ្នំតូចមួយ ក្បែរច្រាំងទន្លេបួនមុខ ។



ថ្ងៃមួយ ទីនោះមានភ្លៀងធ្លាក់ខ្លាំង ទឹកទន្លេជន់លិចរហាចរហឹម ដូនពេញ បានចុះទៅកំពង់ទឹក ស្រាប់តែឃើញដើមគគីរធំមួយអណ្តែតមកក្បែរច្រាំង ហើយដោយអំណាចទឹកហូរសងចុះឡើង ដើមគគីរនោះចេះតែអណ្តែតវិលវល់នៅក្បែរច្រាំងនោះ។ ដូនពេញ ឃើញដូច្នោះ ក៏ប្រញាប់ទៅអំពាវនាវហៅអ្នកជិតខាងឲ្យមកជួយទាញយកដើមគគីរនោះ។ អ្នកជិតខាងក៏នាំគ្នាយកពួរទៅចង ហើយអូសដើមគគីរនោះមកដល់មាត់ច្រាំង។ ពេលដែលដូនពេញយកកំណាត់ឈើទៅកោសកៀរសម្អាតភក់ចេញ គាត់ក៏បានឃើញព្រះពុទ្ធរូប៤អង្គធ្វើពីសំរឹទ្ធ និងទេវរូបមួយអង្គទៀតធ្វើអំពីថ្ម ដែលមានព្រះហស្ដម្ខាងកាន់ដំបង ឯម្ខាងទៀតកាន់ស័ង្ខ (ទំនងជារូបព្រះនារាយណ៍) នៅក្នុងប្រហោងឈើគគីរនោះ ។



ដូនពេញ និងអ្នកជិតខាងដែលទៅជួយមានសេចក្ដីត្រេកអរណាស់ ដោយបានឃើញរបស់ជាទីគោរព រួចក៏នាំគ្នាដង្ហែព្រះបដិមាទាំងនោះមកផ្ទះដូនពេញ និងបានសង់ខ្ទមបណ្ដោះអាសន្នមួយសម្រាប់តម្កល់បដិមាទាំងនោះ។ ក្រោយមក ដូនពេញ បានអំពាវនាវឲ្យអ្នកជិតខាងជួយលើកដីពូនភ្នំ ដែលនៅខាងលិចផ្ទះរបស់គាត់ឲ្យទៅជាភ្នំធំមួយ។ បន្ទាប់មក គាត់ឲ្យ

គេអារឈើគគីរនោះធ្វើជាសសរវិហារ ដែលគាត់បម្រុងសង់នៅលើភ្នំនោះ ។

ក្នុងគ.ស.១៣៧២ ដូនពេញ និងអ្នកស្រុកបានស្រុះស្រួលបបួលគ្នាសាងសង់ព្រះវិហារមួយខ្នង ប្រក់ស្បូវភ្លាំងនៅលើកំពូលភ្នំនោះ ដោយបានដង្ហែព្រះពុទ្ធរូបអំពីសរីទ្ធទាំង៤អង្គយកមកតម្កល់ទុកក្នុងព្រះវិហារផង។ ចំណែកឯទេវរូបថ្ម គាត់បានដង្ហែទៅតម្កល់ទុកលើអសនៈមួយនៅជើងភ្នំខាងកើត ដោយសន្មតនាមថា "អ្នកតាព្រះចៅ" ជាប់រហូតមកដល់សព្វថ្ងៃនេះ ។




កាលសាងសង់វិហាររួចស្រេចបាច់ហើយ ដូនចាស់បានរៀបចំនិមន្តព្រះសង្ឃមកគង់នៅឯជើងភ្នំនៅទិសខាងលិច ទើបប្រាកដឈ្មោះថា "វត្តភ្នំដូនពេញ" ដែលសព្វថ្ងៃហៅកាត់ថា "វត្តភ្នំ" ចាប់ពីពេលនោះរហូតមកដល់សព្វថ្ងៃ។ នេះជាដំណើរដើមទងនៃកំណើតរាជធានីភ្នំពេញ ដែលរវាង៦០ឆ្នាំក្រោយមក រាជធានីនេះក៏ក្លាយជារាជធានីយ៉ាងស្កុកស្តម្ភរបស់ខ្មែរ។



## ២. ភ្នំពេញក្នុងរជ្ជកាលព្រះបាទពញាយ៉ាត

ការស្ថាបនារាជធានីភ្នំពេញលើកទី១ តាមព្រះរាជពង្សាវតារចែងថាព្រះបាទពញាយ៉ាត ទ្រង់គ្រងរាជសម្បត្តិនៅអង្គរបាន១៥ឆ្នាំ។ លុះដល់គម្រប់១៦ឆ្នាំនៃរជ្ជកាលរបស់ព្រះអង្គ ទ្រង់បានយល់ថានឹងទ្រាំរស់នៅក្នុងមហានគរនេះតទៅទៀតពុំបាន ទ្រង់ក៏បញ្ជាឲ្យមន្ត្រីរកទីដីជ័យភូមិថ្មីសម្រាប់កសាងរាជធានីដែលមានទីតាំងនៅម៉ុំទួលបាសាណ ក្នុងខេត្តស្រីសឈរ សព្វថ្ងៃគឺស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ។

នាថ្ងៃ១៣រោច ខែមិគសិរ ឆ្នាំជូត ចត្វាស័ក ព.ស.១៩៧៦ ច.ស.៧៩៤ ត្រូវនឹងគ.ស. ១៤៣២ ព្រះបាទពញាយ៉ាត ទ្រង់បានយាងចេញចាកមហានគរមួយអន្លើដោយព្រះទីនាំងតាមជលមាគ៌ា ដែលមានរាជសេវកាមាត្យ នាម៉ឺនសព្វមុខមន្ត្រីហែហម ។

លុះថ្ងៃ១៥កើត ខែបុស្ស ឆ្នាំជូត ចត្វាស័ក ស្តេចយាងដល់ទួលបាសាណ។ ទ្រង់គង់ជាសុខសាន្តក្នុងព្រះរាជវាំងបាសាណនោះបានត្រឹមតែជាងមួយឆ្នាំប៉ុណ្ណោះ ដោយទឹកទន្លេតែងតែឡើងចុះៗ ធ្វើឲ្យទីនោះលិចជារៀងរាល់ឆ្នាំ ទើបព្រះអង្គមានព្រះរាជបញ្ជាឲ្យសម្តេចចៅពញាកែ និងឧកញ៉ាហោរាធិបតីខៀវ ព្រមជាមួយមន្ត្រីដែលស្គាល់ទីដីជ័យភូមិ ឲ្យពិនិត្យមើលទីដីនៅមុំស្រុកឫស្សីកែវជិតភ្នំដូនពេញ។ ដោយឃើញថា ទីដីនៅទិសអាគ្នេយ៍ភ្នំដូនពេញមានទីដីជ័យភូមិល្អសមល្មមហើយ ព្រះអង្គក៏មានព្រះរាជបញ្ជាឲ្យកសាងព្រះរាជវាំងថ្មីនៅត្រង់នោះតែម្តង ។



នៅថ្ងៃ៩កើត ខែពិសាខ ឆ្នាំខាល ឆស័ក ព.ស.១៩៧៨ ច.ស.៧៩៦ ត្រូវនឹងគ.ស. ១៤៣៤ ព្រះបាទពញាយ៉ាត ស្តេចយាងចាកចេញព្រះបរមរាជវាំងទួលបាសាណ នៅថ្ងៃ១៥កើត ខែពិសាខ ហើយចូលមកគង់ក្នុងព្រះរាជវាំងដែលទើបសាងសង់ថ្មី នាទិសអាគ្នេយ៍នៃភ្នំដូនពេញ ។

ថ្ងៃ១១រោច ខែពិសាខ ឆ្នាំម្សាញ់ នព្វស័ក ព.ស.១៩៨១ ច.ស.៧៩៩ ត្រូវនឹងគ.ស. ១៤៣៧ ព្រះអង្គប្រទាននាមក្រុងថ្មីនេះថា "ក្រុងចតុម្មុខមហានគរភ្នំដូនពេញ" ដូច្នោះ ដើម្បីកុំឲ្យបាត់ឈ្មោះនិងកេរដំណែលរបស់ដូនពេញ។ រីឯទន្លេបួនមុខដែលគេធ្លាប់ហៅថាទន្លេច្រាបឈាមជាយូរមកហើយនោះ ទ្រង់ប្រទានឈ្មោះថា "ទន្លេចតុម្មុខ" វិញ។ ព្រះអង្គទ្រង់បញ្ជាឲ្យឧកញ៉ាតេជោស្រី ចៅហ្វាយស្រុកសំរោងទង ជាអ្នកកាន់ការលើកដីចាក់បំពេញរាជធានីថ្មី

ព្រមទាំងលើកដីបំពេញ "ភ្នំដូនពេញ" ឲ្យរីកធំខ្ពស់ឡើង ឯទីដែលគេជីកយកដីដើម្បីចាក់បំពេញរាជធានីថ្មីនោះមានឈ្មោះថា "បឹងតេជោ" តរៀងមក (បឹងនោះស្ថិតនៅម្តុំផ្សារធំថ្មីសព្វថ្ងៃនេះ)។ ទ្រង់មានព្រះរាជបញ្ជាឲ្យឧកញ៉ាវង្សាអនុជិតផ្លុង កាលណោះគាត់ជាចៅហ្វាយស្រុកបាទី ឲ្យជីកព្រែកមួយ ក្រោយមកហៅថា "ព្រែកពាមផ្លុង" គឺត្រង់ម្តុំសួនច្បារស្ថិតនៅខាងកើតព្រះសក្យមុនីចេតិយមុខស្ថានីយអយស្ម័យយានសព្វថ្ងៃ។ ក្រៅពីនេះ ព្រះបាទពញាយ៉ាត ទ្រង់មានព្រះរាជបញ្ជាឲ្យកសាងវិហារលើទីដីខ្ពស់ ដោយចាក់បំពេញដីថ្មីត្រង់កន្លែងវិហារចាស់របស់ដូនពេញ និងចាត់ឲ្យកសាងព្រះចេតិយធំមួយខាងក្រោយវិហារ។ ទ្រង់បញ្ញត្តឲ្យហៅវត្តភ្នំដូនពេញថា "វត្តព្រះចេតិយបពិត" ដូច្នេះវិញ ។



លុះចំណេរកាលតមក មហាជនបែរជាហៅវត្តភ្នំដូនពេញថា "វត្តភ្នំ" ជាប់រហូតមក។ ទ្រង់មានព្រះរាជបញ្ជាឲ្យកសាងវត្តចំនួនទៀតគឺ: ១- វត្តកោះ ស្ថិតនៅខាងកើតឆៀងអាគ្នេយ៍ភ្នំដូនពេញ ២-វត្តលង្កា ស្ថិតនៅខាងកើតឆៀងឦសានភ្នំដូនពេញ ៣- វត្តព្រះពុទ្ធឃោសា ស្ថិតនៅខាងត្បូងព្រែកចិនដំដែក និងខាងជើងភ្នំដូនពេញ។ ការរៀបចំបែបនេះមិនមែនជាការចៃដន្យឡើយ គឺក្នុងបំណងរំលឹកដល់រឿងមួយដែលដំណាលថា "ព្រះពុទ្ធឃោសាចារ្យ" ទៅចម្លងគម្ពីរពីកោះលង្កា។ ៤- វត្តពាមផ្លុង នៅក្រោមទិសអាគ្នេយ៍ភ្នំដូនពេញ ជាប់នឹងមាត់ព្រែកឧកញ៉ាផ្លុង មិនឆ្ងាយប៉ុន្មានពីវត្តកោះ។ ៥- វត្តឧណ្ណាលោម ជានាមព្រះចេតិយដែលបញ្ចុះព្រះឧណ្ណាលោម(រោមប្រជុំចិញ្ចើម) នៃព្រះអស្សជិតថេរ នៅចំកណ្តាលចេតិយទាំងប្រាំខាង

លិចវិហារវត្តឧណ្ណាលោមសព្វថ្ងៃនេះ។ ៦- វត្តខ្ចបតាយ៉ង យកតាមឈ្មោះជីតាម្នាក់ឈ្មោះយ៉ង ដែលបច្ចុប្បន្នហៅថា "វត្តបុទុមវតី" ។



បន្ទាប់មក ព្រះបាទពញាយ៉ាត ទ្រង់បញ្ជាឲ្យជីកព្រែកមួយទៀតនៅខាងត្បូងព្រះបរមរាជវាំង និងលើកកំពែងធ្វើបន្ទាយព័ទ្ធជុំវិញក្រុង ម្យ៉ាងដើម្បីបានទឹកសម្រាប់ប្រើប្រាស់ និងស្រោចស្រពដំណាំកសិកម្ម ព្រែកនោះមានឈ្មោះថា "ព្រែកតាកែវ" ហួសពីព្រែកនេះទៅលិចមានអូរមួយឈ្មោះថា "អូរគរ" ឯព្រែកមួយទៀតដែលនៅខាងជើងវត្តភ្នំ ហៅថា "ព្រែកពោងពាយ" ក្រោយមកហៅ "ព្រែកចិនដំដែក"។ ចំណែកនៅតាមមាត់ទន្លេបួនមុខ ព្រះរាជាទ្រង់បញ្ជាឲ្យលើកដីជាកំពែង ដើម្បីការពារទឹកទន្លេជន់លិចរាជធានី។ ខាងក្នុងកំពែងជាលំនៅដ្ឋានរបស់អ្នកស្រុក និងពួកអ្នកធ្វើរាជការ។ ឯភូមិភាគខាងលិចក្រុងជាវាលស្រែដ៏ធំល្វឹងល្វើយ។ បួនឆ្នាំក្រោយមក ព្រះនារាយណ៍រាជា ដែលជាបុត្រច្បងរបស់ព្រះបាទពញាយ៉ាត ត្រូវបានតែងតាំងជាព្រះឧបរាជ ទ្រង់មានរាជដំណាក់នៅជ្រោយរលួស។ ចំណែកព្រះស្រីរាជា ជាបុត្របន្ទាប់ទ្រង់គង់នៅខាងលិចអូរគរត្រង់ម្តុំទីទួល សព្វថ្ងៃហៅថា "ទួលព្រះស្រី" ស្ថិតនៅខាងជើងវត្តព្រះពុទ្ធមានបុណ្យ ។



ក្រោយពីព្រះបាទពញាយ៉ាត ទ្រង់សោយទិវង្គតទៅ សង្គ្រាមក្នុងស្រុកតែងកើតឡើងជាហូរហែ ឯរាជធានីក៏តាំងផ្លាស់ទីទៅច្រើនកន្លែងដូចជា ពោធិ៍សាត់ បរិបូណ៌ លង្វែក ឧត្តុង្គ។ល។ លុះមកដល់គ.ស.១៨៦៥ ក្នុងរាជ្យព្រះបាទនរោត្តម ព្រះអង្គបានមកតាំងរាជធានីនៅភ្នំពេញវិញ ក្នុងដំណាក់កាលទីពីរនេះឯង។ គប្បីរំលឹកដែរថា ពេលនោះរាជធានីគឺស្ថិតនៅឧត្តុង្គនៅឡើយទេ ។

## ៣. ភ្នំពេញសម័យអាណានិគមបារាំង

នៅគ.ស.១៨៦៦ ព្រះបាទនរោត្តម ទ្រង់បានសម្រេចព្រះទ័យចាកចេញពីរាជវាំងឧត្តុង្គមកកាន់ភ្នំពេញ។ គ្រានោះតំបន់នេះជាភូមិតូចមួយនៅតាមបណ្តោយច្រាំងទន្លេ។ លំនៅដ្ឋានរបស់ប្រជាជនច្រើនធ្វើអំពីឫស្សីដំបូលប្រក់ស្លឹក មានរបរជាអ្នកនេសាទ និងធ្វើស្រែចម្ការ។ ក្រៅពីសាសន៍ខ្មែរ មានសាសន៍ដទៃទៀតដែរដូចជា ចិន យួន ជ្វា ដែលជាអ្នកជំនួញ និងនេសាទ ។

ចន្លោះគ.ស.១៨៦៦ ដល់គ.ស.១៨៩០ ព្រះបាទនរោត្តម ទ្រង់មាននយោបាយថ្មី គឺការពង្រីកទីក្រុងឲ្យមានភាពប្រសើរឡើង ដោយបានស្ថាបនាអគារថ្មីៗជាច្រើន ជំនួសឲ្យផ្ទះឫស្សីប្រក់ស្លឹក ជាពិសេសផ្ទះនៅតាមដងទន្លេ។ ចាប់ពីគ.ស.១៨៩០ វិស្វករបារាំងបានរៀបចំប្រព័ន្ធបង្ហូរទឹក និងស្ថាបនាផ្លូវថ្នល់ខ្វាត់ខ្វែង ដោយចម្លងតាមគំរូស្ថាបត្យកម្មនៅក្រុងប៉ារីស។ ភ្នំពេញសម័យនោះបានបែងចែកជាបីសង្កាត់នៅរៀងគ្នាពីជើងទៅត្បូងហើយសំគាល់ដោយក្រុមជាតិសាសន៍ដែលរស់នៅក្នុងសង្កាត់នីមួយៗ។ នៅខាងជើងក្បែរវត្តភ្នំ ជាសង្កាត់បារាំង

(អឺរ៉ុប) ដែលមានព្រំប្រទល់ជាប់នឹងព្រែកជីកមួយ។ នៅអាយខាងត្បូង ម្តុំផ្សារកណ្តាលជាសង្កាត់ចិននៅព័ទ្ធជុំវិញផ្សារ ដែលមានព្រំប្រទល់ជាប់នឹងព្រែកពាមផ្លូង ហើយខាងត្បូងជាប់នឹងវាលព្រះមេរុ។ ឯសង្កាត់ខ្មែរវិញស្ថិតនៅម្តុំព្រះរាជវាំង ដោយសន្ទឹងទៅត្បូង ។





ក្រោយការចូលទិវង្គតរបស់ព្រះបាទនរោត្តម នៅគ.ស.១៩០៤ ព្រះបាទស៊ីសុវត្ថិ ស្នងរាជ្យបន្ត។ ព្រះអង្គបានបន្តរៀបចំរាជធានីឲ្យកាន់តែទំនើប ដោយមានការស្ថាបនាអគារសាធារណៈជាច្រើន និងបានពង្រីកសង្កាត់នីមួយៗ ដូចបានជូនជ្រាបពីខាងដើមឲ្យកាន់តែធំ ។



# ៤. ភ្នំពេញសម័យសង្គមរាស្ត្រនិយម

ក្រោយឯករាជ្យគ.ស.១៩៥៣ ប្រទេសកម្ពុជាត្រូវបានគេទទួលស្គាល់ថាជា "កោះសន្តិភាព"។ ឯទីក្រុងភ្នំពេញបានពង្រីកខ្លួនយ៉ាងឆាប់រហ័ស និងមានប្រជាជនរស់នៅច្រើនកុះករ។ សន្ទុះសេដ្ឋកិច្ចនាទស្សវត្ស១៩៦០ ដែលកើតមកពីការកើនឡើងនៃកសិកម្ម ជំរុញឲ្យ

មានការធ្វើជំនួញ និងរកស៊ីច្រើននៅតំបន់ក្រុង។ ជំនាន់នោះការរៀបចំក្រុងស្ថិតក្នុងបរិបទតាមបែបទគរោបនីយកម្មរបៀបបារាំងនាសតវត្សទី២០ ដោយបានកសាងបន្ថែមនូវហេដ្ឋារចនាសម្ព័ន្ធ មានផ្លូវថ្នល់ ស្ពាន សាលារៀន សាកលវិទ្យាល័យនានា ក្រសួងផ្សេងៗ មន្ទីរពេទ្យ វិមានឯករាជ្យ រោងមហោស្រព សារមន្ទីរ និងពហុកីឡដ្ឋានជាតិជាដើម។ល។

## ៥. ភ្នំពេញក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ប៉ុល ពត)

ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដំណើរវិវឌ្ឍន៍ក្នុងវិស័យរៀបចំក្រុងនេះ ត្រូវបានគាំងស្ទះយ៉ាងទាន់ហន់ ពេលដែលប្រទេសកម្ពុជាស្ថិតក្នុងការគ្រប់គ្រងរបស់ពួកខ្មែរក្រហមសម្លាប់ជាតិឯង អំឡុងគ.ស.១៩៧៥ ដល់ដើមគ.ស.១៩៧៩ ។

ប្រជាជនត្រូវបានជម្លៀសចេញពីក្រុង ខ្លះទៀតចាកឆ្ងាយពីភូមិឋាន ស្រុកកំណើត បំបិទសិទ្ធិសេរីភាពទាំងស្រុង និងបង្ខំឲ្យធ្វើការបាក់កំលាំងជាងទាសករដាច់ថ្លៃ។ តម្លៃនិងភាពជាមនុស្សពេលនោះមិនស្មើនឹងបបរមួយវែកបាយផង ឬពោលម្យ៉ាងទៀតថា តម្លៃមនុស្សអន់ជាងតិរច្ឆានផងក៏ថាបាន។ ភាពក្រីក្រ ព្រមទាំងភាពឯកោ ជំរុញឲ្យកម្ពុជាធ្លាក់ក្នុងកម្រិតក្រោមសូន្យ។ គ្រប់ហេដ្ឋារចនាសម្ព័ន្ធត្រូវបានបំផ្លិចបំផ្លាញយ៉ាងធ្ងន់ធ្ងរ ហើយរាជធានីភ្នំពេញបានក្លាយជាទីក្រុងខ្មោច។





www.phnompenh.gov.kh

# ៦. ភ្នំពេញសម័យតេជោសែន

ក្រោយថ្ងៃរំដោះ ៧ មករា ឆ្នាំ១៩៧៩ ភ្នំពេញបានរស់ឡើងវិញ ក្រោមទង់រណសិរ្ស សាមគ្គីសង្គ្រោះជាតិ ដោយបានខិតខំត្រដររក្រោកឈរទាំងទុព្វលភាព ក្នុងសភាពខ្វះសព្វ ខ្វះគ្រប់ បោះជំហានអភិវឌ្ឍន៍បណ្ដើរៗ ពីស្ថានភាពសោះកក្រោះ មកកាន់ស្ថានភាពស្រស់ថ្លា។ នាសហសវត្សថ្មីនេះ កម្ពុជាបានឆ្លងផុតពីយុគដ៏ខ្មៅងងឹតមួយ ហើយបច្ចុប្បន្នបានទទួលនូវសុខសន្តិភាពដ៏ពេញលេញ ស្ថិរភាពនយោបាយ ព្រមទាំងជាសម័យមួយប្រកបដោយសន្តិភាព ការអភិវឌ្ឍ និងកិច្ចសហប្រតិបត្តិការ ដែលអាចសម្លឹងទៅរកអនាគតដ៏វែងឆ្ងាយរបស់ខ្លួន ក្នុងចំណោមប្រទេសជិតខាងនៅអាស៊ី ក៏ដូចជាសកលលោកទាំងមូល ។

នេះដោយមានការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល ដែលមានសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ជាអគ្គមគ្គុទេសន៍ដ៏ឆ្នើម ប្រកបដោយគតិបណ្ឌិត និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត ដឹកនាំដ៏ត្រឹមត្រូវក្នុងការស្ដារនិងអភិវឌ្ឍប្រទេស ដោយបានធ្វើការពួតដៃគ្នាយ៉ាងជិតស្និទ្ធជាមួយស្ថាប័នថ្នាក់ក្រោមជាតិ អង្គការសង្គមស៊ីវិល អាជ្ញាធរ រួមទាំងដៃគូទាំងអស់ ទាំងជាតិ និងអន្តរជាតិ ក្នុងបំណងសម្រេចឲ្យបាននូវការអភិវឌ្ឍសហសវត្សរ៍។



## ៦.១. ការងារសន្តិសុខ និងការគ្រប់គ្រងរដ្ឋបាលដែនដី

ភ្នំពេញ ជារាជធានី និងជាទីក្រុងធំជាងគេបំផុតនៃប្រទេសកម្ពុជា ជាមជ្ឈមណ្ឌលសន្តិសុខ នយោបាយ សេដ្ឋកិច្ច វប្បធម៌ និងការទូត ។ រាជធានីនេះមានការកែសម្រួលដែនដីព្រំប្រទល់ ជាបួនដំណាក់កាល ក្រោយរបបប្រល័យពូជសាសន៍ប៉ុលពត។

ដំណាក់កាលទាំងបួននោះមាន៖

* លើកទី១ ៖ ការបញ្ចូលស្រុកដង្កោ
* លើកទី២ ៖ ការបង្កើតខណ្ឌឫស្សីកែវ
* លើកទី៣ ៖ ការបញ្ចូល៤ភូមិរបស់ឃុំកន្ទោក មកក្នុងដែនដីរដ្ឋបាលរាជធានីភ្នំពេញ
* លើកទី៤ ៖ ការបញ្ចូល២០ឃុំ របស់ស្រុក៥ (ពញាឮ, មុខកំពូល, កៀនស្វាយ, កណ្ដាលស្ទឹង, អង្គស្នួល) នៃខេត្តកណ្ដាល មកក្នុងដែលដីរដ្ឋបាលរាជធានីភ្នំពេញ។




## ភូមិសាស្ត្រ

ភ្នំពេញស្ថិតនៅក្នុងតំបន់ខាងត្បូង-កណ្ដាលនៃប្រទេសកម្ពុជា នៅចំណុច ប្រសព្វនៃទន្លេសាប ទន្លេមេគង្គ និងទន្លេបាសាក់។ ទន្លេទាំងនេះផ្ដល់នូវ ប្រព័ន្ធអេកូឡូស៊ីទឹកសាប និងទន្លេប្រកបដោយសក្ដានុពលជាធនធាន ដ៏សំខាន់សម្រាប់លក្ខខណ្ឌ បរិស្ថានប្រកបដោយចិរភាព សោភ័ណភាព ធម្មជាតិ និងវប្បធម៌ ប្រកបដោយភាពចម្រុងចម្រើនសម្រាប់ប្រជាជននៅរាជធានីភ្នំពេញ តាំងពីអតីតកាលរហូតមកដល់បច្ចុប្បន្ន ។

www.phnompenh.gov.kh

# ផែនទីភូមិសាស្ត្ររបស់រាជធានីភ្នំពេញឆ្នាំ២០១០



www.phnompenh.gov.kh

## ៦.២. ការងារអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ និង សេដ្ឋកិច្ច













# ៦.៣. វិស័យអប់រំ សុខាភិបាល សង្គមកិច្ច វប្បធម៌ និងសាសនា













## ៦.៤. ការងារលើកកម្ពស់គុណភាពបរិស្ថាន និងផ្គត់ផ្គង់ទឹកស្អាត













## ៦.៥. ការងារលើកកម្ពស់យេនឌ័រក្នុងកិច្ចអភិវឌ្ឍន៍សង្គម











# ៧. វត្តភ្នំៈ ការអភិរក្ស និងអភិវឌ្ឍ



ក្រោមនិន្នាការខិតទៅជិត និងឈានទៅសម្រេចឲ្យបាននូវគោលដៅនៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល និងគោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា សាលារាជធានីភ្នំពេញបានធ្វើការកែលម្អបរិស្ថានជាបន្តបន្ទាប់ និងធ្វើការថែរក្សាកេរមត៌កបេតិកភណ្ឌជាតិ ដែលការងារទាំងនោះរួមមានៈ ការងារអភិរក្ស និងចុះបញ្ជីចេតិយវត្តភ្នំ នៅជុំវិញវត្តភ្នំ មានសំណង់សំខាន់ៗដូចជា ព្រះវិហារព្រះសិអារ្យមេត្រីយ៍ ចេតិយស្តេចពញាយ៉ាត (ចេតិយធំកណ្តាល) វិហារអ្នកតាព្រះចៅ សារមន្ទីរ ព្រះវិហារតូច បញ្ញរលក់សំបុត្រ ឆាកសំដែងសិល្បៈ ទូងស្គរ អសនៈ លោកយាយពេញ សាលពិព័រណ៍ និងចេតិយតូចចំនួន៣០ទៀតដែលបានស្រាវជ្រាវ និងចុះបញ្ជីរួចហើយ ។



*ចេតិយព្រះបាទស៊ីសុវត្ថិ គ.ស.១៩០៤-១៩២៧ (រូបថតគ.ស.២០០៨)*

ជាមួយនេះ សាលារាជធានីភ្នំពេញ បាននឹងកំពុងចូលរួមអនុវត្តយុទ្ធសាស្ត្រចតុកោណ របស់រាជរដ្ឋាភិបាល ក្នុងការថែរក្សាការពារបេតិកភណ្ឌ និងអត្តសញ្ញាណជាតិ ព្រមទាំងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធមធ្យោបាយធ្វើដំណើរសមស្រប សំណង់នានា ដោយឈរលើចក្ខុវិស័យ «ទីក្រុងទំនើប»។

ទីក្រុងភ្នំពេញមានភ័ព្វសំណាង ដែលនៅសេសសល់អគារសាធារណៈ វត្តអារាម និងផ្ទះបុរាណខ្មែរមួយចំនួន ជាសក្ខីភាពបង្ហាញពីប្រភេទស្ថាបត្យកម្មរចនាបថច្រើនបែប ជាពិសេសគឺ វត្តភ្នំ ។

## ៧.១. ការជួសជុល និងកែលម្អវត្តភ្នំ

ការអភិរក្ស និងអភិវឌ្ឍ គឺជាកាតព្វកិច្ចចាំបាច់របស់សាលារាជធានីភ្នំពេញ ដើម្បីរក្សាបាននូវអត្តសញ្ញាណ ក៏ដូចជាបេតិកភណ្ឌជាតិ។ សាលារាជធានីភ្នំពេញ បានធ្វើការជួសជុលកែលម្អវត្តភ្នំ ដោយសហការ និងផ្តល់ជំនួយពីរដ្ឋាភិបាលបារាំង តាមរយៈស្ថានទូតបារាំងប្រចាំនៅកម្ពុជា រួមមានដូចជា:

- ដឹកដីទន្លេយកទៅចាក់បំពេញជម្រាលវត្តភ្នំ និងរៀបចំដាំស្មៅស្រោចទឹកជាប្រចាំ
- កាប់ដើមឈើចេញពីចេតិយ និងជួសជុលកែលម្អដោយរក្សានូវរចនាបថដើម
- ជួសជុលកែលម្អលាបសំអាតទូទៅ
- ដំឡើងបង្គោលភ្លើង និងរបងព័ទ្ធជុំវិញក្នុងបរិវេណទីធ្លាវត្តភ្នំ
- សាងសង់បញ្ជរចំនួន៤កន្លែង ជុំវិញវត្តភ្នំសំរាប់ការយាមកាមការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ
- រៀបចំក្រាលថ្មបាយក្រៀមពីជម្រាលភ្នំរហូតដល់ទីធ្លាជុំវិញវត្តភ្នំ
- សាងសង់បន្ថែមនូវរូបក្បាលនាគចំនួន២ នៅខាងត្បូងវត្តភ្នំ
- ដំឡើងនាឡិកាធំ និងចាក់ពុម្ពចម្លងរូបសំណាកព្រះបាទស៊ីសុវត្ថិ
- រៀបចំដាំដើមឈើព័ទ្ធជុំវិញនៅចន្លោះដែលខ្វះខាត
- រៀបចំចាក់ដីបន្ថែមនៅទីធ្លាសាលពិព័រណ៍
- រៀបចំប្រព័ន្ធលូបង្ហូរទឹកនៅជុំវិញវត្តភ្នំ
- កែលម្អ និងជួសជុលសាលពិព័រណ៍វត្តភ្នំ

- រៀបចំរូបសំណាកលោកយាយពេញដោយទុកនៅកន្លែងដើមវិញ
- ជួសជុលព្រះវិហារអ្នកតាព្រះចៅ
- គូរគំនូរឡើងវិញតាមគំរូដែលមានស្រាប់ ដោយគ្រាន់តែលាបពណ៌បន្ថែម
- ជួសជុលជណ្តើរ និងរូបចម្លាក់ដែលនៅអមសងខាងជណ្តើរ

បន្ទាប់មក សាលារាជធានីបានធ្វើការជួសជុល និងថែរក្សាវត្តភ្នំ ជាបន្តបន្ទាប់ទៀត រួមមាន៖

- ពង្រឹងទួលឲ្យរឹងមាំ និងដំឡើងភ្លើងបំភ្លឺសាធារណៈ
- ពង្រឹង និងជួសជុលជញ្ជាំងជម្រាលភ្នំ
- ជួសជុលប្រព័ន្ធបង្ហូរទឹកដើម្បីកាត់បន្ថយការលិចទឹក
- ដាំដើមឈើជុំវិញភ្នំ

ដោយទទួលបានជំនួយពីរាជរដ្ឋាភិបាលជប៉ុន សាលារាជធានីភ្នំពេញបានធ្វើការជួសជុល និងសាងសង់គម្របលូបង្ហូរទឹកនៅជុំវិញបរិវេណវត្តភ្នំ។ ទន្ទឹមនឹងនេះ សាលារាជធានីភ្នំពេញ បានធ្វើការកែលម្អសួន និងរៀបចំសួនថ្មី ជាច្រើនបន្ថែមទៀតនៅជុំវិញវត្តភ្នំ។ ធ្វើការជួសជុលលាបសំអាតកន្លែងទូងស្គរជ័យ និងដាំកូនឈើបន្ថែមតាមជម្រាលវត្តភ្នំ។ ក្រៅពីនេះ សាលារាជធានីបានអនុវត្តគំរោងសាងសង់សួនរូបសំណាកលោកយាយពេញ ។



*រូបភាពចេតិយវត្តភ្នំ មើលពីមាត់ទន្លេ គ.ស.១៨៧៣*



ជារថយន្តទី១ធ្វើដំណើរពីភ្នំពេញទៅខេត្តកំពតក្នុងគ.ស.១៩១២

## ក. សកម្មភាពជួសជុល និងថែរក្សាវត្តភ្នំ ឆ្នាំ២០០១



សកម្មភាពដឹកដីពីទន្លេទៅចាក់នៅចំហៀងវត្តភ្នំ ដាំស្មៅ
និងចាក់ពុម្ពបង្គោលភ្លើងបំភ្លឺនៅជុំវិញវត្តភ្នំ



ការរៀបថ្មបាយក្រៀមពីជម្រាលភ្នំរហូតដល់ទីធ្លាជុំវិញទួលភ្នំ



ការជួសជុលប្រព័ន្ធបង្ហូរទឹកដើម្បីកាត់បន្ថយការលិចទឹក



សកម្មភាពដំឡើងបង្គោលភ្លើងព័ទ្ធជុំវិញបរិវេណវត្តភ្នំ



បញ្ជរលក់សំបុត្រ



*ការជួសជុលកន្លែងសម្រាប់ដាក់នាឡិកា និងដាំកូនឈើ
នៅខាងមុខរូបសំណាកព្រះបាទស៊ីសុវត្ថិ*

ក្រោមកិច្ចសហប្រតិបត្តិការជាមួយស្ថានទូតបារាំងប្រចាំនៅកម្ពុជា សាលារាជធានីភ្នំពេញ បានអនុវត្តគម្រោងសាងសង់បន្ថែមនូវ ក្បាលនាគពីរខាងត្បូងវត្តភ្នំ និងរៀបចំពិធីបុណ្យឆ្លងបញ្ចប់គម្រោងជួសជុលនៅបរិវេណវត្តភ្នំ ។





*ព្រះសង្ឃសម្តែងធម៌ទេសនា ព្រោះព្រំ និងសុន្ទរកថារបស់
ឯកឧត្តមឯកអគ្គរដ្ឋទូតបារាំងប្រចាំនៅកម្ពុជា*



សាលពិព័រណ៌នៅវត្តភ្នំ



ការចូលរួមរបស់ប្រជាជនយ៉ាងច្រើនកុះករក្នុងពិធីបុណ្យឆ្លងនៅវត្តភ្នំ គ.ស.២០០៨



សួននៅខាងត្បូងវត្តភ្នំត្រូវបានរៀបចំ និងកែលម្អជាថ្មី







វត្តភ្នំ មើលទៅមហាវិថីឌូដាដឺឡាគ្រេ (បច្ចុប្បន្នមហាវិថីព្រះនរោត្តម) នៅគ.ស.១៨៩៨



លោកសេនាប្រមុខ តុហ្វារៈ ជាតិបារាំងមកទស្សនកិច្ចជាផ្លូវការនៅវត្តភ្នំ
នៅដើមគ.ស.១៩២០



ស្ពាននាគ (មើលចំពីមុខវត្តភ្នំ)



មហាវិថីព្រះនរោត្តមមើលចំពីមុខវត្តភ្នំ គ.ស.១៩៩២





ស្ពាននាគ (មើលពីមុខចេតិយ)



រូបភាពវត្តភ្នំ គ.ស.២០០៧

www.phnompenh.gov.kh



នាឡិកាធំនៅវត្តភ្នំ



## ១. ការសិក្សា និងចុះបញ្ជីចេតិយវត្តភ្នំ

នៅជុំវិញវត្តភ្នំ មានចេតិយស្តេចពញាយ៉ាត (ចេតិយធំកណ្តាល) និងចេតិយតូចចំនួន៣០ទៀតដែលបានស្រាវជ្រាវ និងចុះបញ្ជីរួចហើយ មានដូចជាៈ

១- ចេតិយស្តេចពញាយ៉ាត ជាចេតិយប្រភេទធំនៅសម័យកណ្តាល គ.ស.១៤៦២-១៤៦៧ មានកម្ពស់ ៤២,២៥ម៉ ជ្រុង២៦,៦៦ម៉ លក្ខណៈសំណង់គឺរៀបចំពីឥដ្ឋ លាយកំបោរបាយអ។ ចេតិយនេះស្ថិតនៅក្រោយព្រះវិហារធំ (ខាងលិច) និងមានសារសំខាន់ណាស់ ដែលជាគោលសម្រាប់ធៀបនឹងចេតិយតូចៗដទៃទៀត ។





២-ចេតិយ (លេខរៀងទី ២) មានកម្ពស់ ៣,៩០ម៉ ជ្រុង ១,៣៧ ស្ថិតនៅទិសបស្ចឹម ស្ថិតនៅលើខឿនចេតិយធំ។ លក្ខណៈសំណង់គឺ រៀបចំពីឥដ្ឋ និងកំបោរបាយអ ដែលមានរូបរាងកែច្នៃខ្លះៗ ស្រដៀងនឹងចេតិយព្រះបាទស្រីរាជា។




៣-ចេតិយ (លេខរៀងទី ៣) មានកម្ពស់ ៣,២០ម៉ ជ្រុង២,១៧ម៉ ស្ថិតនៅទិសនិរតី នៅផ្នែកខាងក្រោយចេតិយធំ។ លក្ខណៈសំណង់រៀបពីឥដ្ឋ និងកំបោរបាយអ នៅក្នុងសម័យកណ្ដាលចន្លោះសតវត្សទី ១៥-១៦ ។




៤-ចេតិយ (លេខរៀងទី ៤) មានកម្ពស់ ៩,២០ម៉ ជ្រុង៦,០០ម៉ ស្ថិតនៅទិសឦសាន ស្ថិតនៅចង្កេះភ្នំ។ លក្ខណៈសំណង់រៀបពីឥដ្ឋ និងកំបោរបាយអ នៅក្នុងសម័យកណ្ដាល ដែលជាប្រភេទចេតិយមធ្យម (ចេតិយនេះបានបាក់កំពូល ដែលបានធ្វើការជួសជុល និងកែសម្រួល ឱ្យមានលក្ខណៈដូចដើមវិញ)។

www.phnompenh.gov.kh







៥-ចេតិយ (លេខរៀងទី ៥) ជាប្រភេទចេតិយមធ្យម មានកម្ពស់ ៣,២០ម៉ ជ្រុង ៣,៦០ម៉ ស្ថិតនៅចង្កេះភ្នំនាទិសឦសាន។ លក្ខណៈសំណង់រៀបពីឥដ្ឋ និងកំបោរបាយអ មានរូបរាងដូចគ្នាស្ទើរតែទាំងស្រុងទៅនឹងចេតិយព្រះបាទស្រីរាជា ប៉ុន្តែមានការអភិវឌ្ឍផ្នែករចនាបថតួកណ្តាលពីជ្រុងទៅមូលវិញ នៅក្នុងសម័យកណ្តាល ។







៦-ចេតិយព្រះបាទស្រីរាជា (លេខរៀងទី ៦) ជាប្រភេទមធ្យម មានកម្ពស់៧,៤០ម៉ ជ្រុង៣,៦០ម៉ ស្ថិតនៅទិសឦសាន។ លក្ខណៈសំណង់រៀបពីឥដ្ឋ និងកំបោរបាយអ នៅក្នុងសម័យកណ្តាល សតវត្សទី១៥។ ចេតិយនេះត្រូវបានព្រះបាទស៊ីសុវត្ថិ ទ្រង់បង្គាប់ឲ្យចារ

www.phnompenh.gov.kh

សិលាចារឹកនៅទីនោះ (ឆ្នាំម្សាញ់ ទ្វស័ក១៩១៧) ហើយចេតិយនេះដែរ ជាគំរូសម្រាប់សិក្សាប្រៀបធៀបចេតិយមួយចំនួនទៀត ដែលនៅជុំវិញ វត្តភ្នំ។







៧-ចេតិយ (លេខរៀងទី ៧) ជាប្រភេទមធ្យម មានកម្ពស់ ១០,៤០ម៉ ជ្រុង៥,៣០ម៉ ស្ថិតនៅទិសឦសាន នៅជាន់ផ្ទាល់ដីខាងឆ្វេងជណ្ដើរឡើងទៅព្រះវិហារ។ លក្ខណៈសំណង់រៀបពីឥដ្ឋ និងកំបោរបាយអ នៅក្នុងសម័យកណ្ដាល ចន្លោះសតវត្សទី ១៥-១៦។







www.phnompenh.gov.kh

៨-ចេតិយ (លេខរៀងទី ៨) ជាប្រភេទមធ្យម មានកម្ពស់៧,៦០ម៉ ជ្រុង៥,៩០ម៉ ស្ថិតនៅទិសអាគ្នេយ៍ នៅជាន់ផ្ទាល់ដី។ លក្ខណៈសំណង់រៀបពីឥដ្ឋ និងកំបោរបាយអ នៅក្នុងសម័យកណ្តាលសតវត្សទី ១៥ ។







៩-ចេតិយយ (លេខរៀងទី ៩) ជាប្រភេទមធ្យម មានកម្ពស់ ៦,៩០ម៉ ជ្រុង៣,៤២ម៉ ស្ថិតនៅទិសទក្សិណ នៃចេតិយធំ នៅជាន់ផ្ទាល់ដី។ លក្ខណៈសំណង់ រៀបពីឥដ្ឋ និងកំបោរបាយអ នៅក្នុងសម័យកណ្តាល ចន្លោះសតវត្សទី ១៥-១៦ ។







១០-ចេតិយ (លេខរៀងទី ១០) ជាប្រភេទតូច មានកម្ពស់៣,៦៣ម៉ ជ្រុង២,២០ម៉ ស្ថិតនៅទិសទក្សិណនៃចេតិយធំ នៅជាន់ផ្ទាល់ដី។ លក្ខណៈសំណង់រៀបពីឥដ្ឋ និងកំបោរបាយអ នៅក្នុងសម័យកណ្តាល ចន្លោះសតវត្សទី ១៦-១៧ ។

www.phnompenh.gov.kh



Front View



www.phnompenh.gov.kh

## ៧.២. គម្រោងជួសជុលកែលម្អព្រះវិហារវត្តភ្នំ ឆ្នាំ២០១១

១. ទីតាំងភូមិសាស្ត្រព្រះវិហារវត្តភ្នំ

២. ស្ថានភាពសំណង់ព្រះវិហារវត្តភ្នំ មុនពេលជួសជុលកែលម្អ

២.១. ទិដ្ឋភាពសំណង់ព្រះវិហារវត្តភ្នំ

២.២. ស្ថានភាពព្រះវិហារ និងក្បាច់លម្អ

ក. សំណង់គ្រឹះ

ខ. តួព្រះវិហារ

គ. ផ្នែកដំបូល

២.៣. ស្ថានភាពគំនូរ និងរូបចម្លាក់

ក. ទិដ្ឋភាពទូទៅខាងក្នុងព្រះវិហារ

ខ. គំនូរ

គ. រូបចម្លាក់

២.៤. ស្ថានភាព ជញ្ជាំង សសរ និងគ្រឿងបង្គុំឈើ

២.៥. បណ្តាញអគ្គិសនី និងប្រព័ន្ធភ្លើងបំភ្លឺ

៣. ការងារជួសជុល និងកែលម្អព្រះវិហារវត្តភ្នំ

៣.១. ពិធីក្រុងពាលីបើកការដ្ឋានជួសជុលកែលម្អព្រះវិហារវត្តភ្នំ

៣.២. ការងារពង្រឹង ជួសជុល និងកែលម្អផ្នែកសំណង់ព្រះវិហារៈ លេណគ្រឹះ ដំបូល ជញ្ជាំង ធឿន ទ្វារ និងបង្អួច......

ក. ការងារជួសជុលលេណគ្រឹះ

ខ. ការងារជួសជុលផ្នែកដំបូល

៣.៣. ការងារពង្រឹង ជួសជុល និងលាងសំអាតគំនូរលើៈ ជញ្ជាំង ពិតាន ទ្វារ បង្អួច និងសសរ

ក. ការថតរូបគំនូរដើម្បីចងក្រងជាឯកសារ

ខ. ការជួសជុល ពង្រឹង និងលាងសំអាតគំនូរ

គ. ការប្រៀបធៀបរូបគំនូរ មុន និងក្រោយពេលជួសជុល និងលាងសំអាត

៣.៤. ការងារពង្រឹង ជួសជុល និងលាងសំអាតរូបចម្លាក់ៈ ព្រះអង្គធំ បុស្បុក និងពុទ្ធបដិមា

៣.៥. ការងាររៀបចំបណ្តាញអគ្គិសនីថ្មីៈ បំពាក់ខ្សែភ្លើង ទូបញ្ជា អំពូលភ្លើង

www.phnompenh.gov.kh

និងដំឡើងបង្គោលភ្លើង

៣.៦. ការងារជួសជុលកែលម្អបរិវេណលើភ្នំ ដើម្បីសម្រួលដល់ការ

ទស្សនារបស់ភ្ញៀវ.........

ក. ការជួសជុលកម្រាលខឿន

ខ. ការជួសជុលជណ្តើរខាងជើងព្រះវិហារ

គ. ការជួសជុលជើងបង្គោលភ្លើង

៤. លទ្ធផលសម្រេចនៃគម្រោងជួសជុលកែលម្អព្រះវិហារវត្តភ្នំ

www.phnompenh.gov.kh

# ១. ទីតាំងភូមិសាស្ត្រ ព្រះវិហារវត្តភ្នំ













ប្លង់ផ្ដេក ព្រះវិហារវត្តភ្នំ

## ២. ទិដ្ឋភាពព្រះវិហារវត្តភ្នំ

ព្រះវិហារវត្តភ្នំនេះជាប្រភេទព្រះវិហារជហ្វា៤ (កំណត់តាមចំនួនជហ្វាលើដំបូល) នៅលើខឿនខ្ពស់ និងសង់ពីឥដ្ឋ ប្រក់ក្បឿងស្រកាលេញពណ៌។ ផ្នែកខាងក្នុងព្រះវិហារមានគំនូរពណ៌ទាក់ទងរឿងពុទ្ធប្រវត្តិ នៅលើពិតាន ជញ្ជាំង និងសសរ ។ ទំហំតួ និងខឿនព្រះវិហារមានដូចខាងក្រោម៖

- តួព្រះវិហារៈ ទទឹងៈ ១១.៦ ម. បណ្ដោយៈ ២២.៣ ម. កម្ពស់សរុបៈ ១០.៧ ម.
- ខឿន ៈ ទទឹងៈ ១៧ ម. បណ្ដោយៈ ២៥ ម. កម្ពស់ៈ ១.៦ ម.



រូបភាពមើលពីមុខ



www.phnompenh.gov.kh

សំណង់ព្រះវិហារវត្តភ្នំ សង់នៅលើខឿនមានផ្ទៃសរុប៤៣៥ម$^{២}$ ចែកជា៣ថ្នាក់ ដែលថ្នាក់នីមួយៗមានកំពស់ និងទំហំផ្ទៃខុសៗគ្នា *(បញ្ជាក់៖ កម្ពស់ គិតពីពិតានបេតុងដល់ជើងតាងសសរ)*

- ថ្នាក់ទី១ កម្ពស់ ១.៤០ម មានផ្ទៃប្រហែល ២០០ម$^{២}$
- ថ្នាក់ទី២ កម្ពស់ ១.៨០ម មានផ្ទៃប្រហែល ៨០ម$^{២}$
- ថ្នាក់ទី៣ កម្ពស់ ២.១០ម មានផ្ទៃប្រហែល ១៥៥ម$^{២}$



ប្លង់បង្ហាញពីកម្រិតកម្ពស់នៃថ្នាក់ទាំង៣ក្នុងលេណគ្រឹះព្រះវិហារវត្តភ្នំ



ប្លង់បង្ហាញពីកម្រិតកម្ពស់នៃថ្នាក់ទាំង៣ និងទិដ្ឋភាពផ្ទៃលេណគ្រឹះនៃព្រះវិហារវត្តភ្នំ



រូបភាពវត្តភ្នំ (ឆ្នាំ១៩០១)



រូបភាពវត្តភ្នំ (ឆ្នាំ២០១០)



រូបភាពព្រះវិហារវត្តភ្នំ (ឆ្នាំ១៩០៦)



រូបភាពព្រះវិហារវត្តភ្នំ (ឆ្នាំ២០១០)



រូបភាពព្រះវិហារវត្តភ្នំ (ឆ្នាំ១៩៣០)



រូបភាពព្រះវិហារវត្តភ្នំ (ឆ្នាំ២០១០)



រូបភាពព្រះវិហារវត្តភ្នំ (ឆ្នាំ១៩៣០)



រូបភាពព្រះវិហារវត្តភ្នំ (ឆ្នាំ២០១០)

# ២.១. ស្ថានភាពសំណង់ព្រះវិហារវត្តភ្នំ

## ក. សំណង់គ្រឹះ

<u>ស្ថានភាព:</u>

– គ្រឹះនៅក្នុងលេណគ្រឹះ ប៉ែកខាងកើតជ្រុងខាងជើង មានស្នាមជ្រាប និងដក់ទឹក ដែលទំនងជាកើតមានជាយូរមកហើយ។

– ស្ថានភាពនេះបណ្តាលឲ្យខឿនប៉ែកខាងជើងស្រុតចុះបើប្រៀបធៀបទៅនឹងខឿន នៅជ្រុងខាងត្បូង។

– កត្តានេះក៏ជាមូលហេតុបណ្តាលឲ្យជញ្ជាំងវិហារនៅជ្រុងទិសឦសានមានស្នាម ប្រេះ។

<u>ដំណោះស្រាយ:</u>

– ពង្រឹងគ្រឹះ និងដី ដែលមានទឹកដក់ ដោយបញ្ចៀសទឹកកុំឲ្យហូរចូលក្នុងលេណគ្រឹះ។

– ជួសជុលស្នាមប្រេះ។

– ចាក់សាបផ្ទៃបាត និងបូកពិតាន។

រូបភាពគ្រឹះព្រះវិហារ បង្ហាញទីតាំងជ្រាបទឹក និងទីតាំងស្រុតប្រេះ









ទីតាំងលេណគ្រឹះ ដែលមានស្នាមជ្រាប និងស្នាមទឹកហូរ





ស្នាមប្រេះនៅជញ្ជាំងព្រះវិហារ ដោយសារខឿននៅប៉ែកខាងជើងស្រុតចុះ





ទ្វារចូលលេណគ្រឹះតូចចង្អៀតពិបាកចេញចូល និងវត្ថុផ្សេងៗដែលមិនប្រើបានទុក គរក្បែរមាត់ច្រកខាងក្នុង

នៅក្នុងលេណគ្រឹះមានបំពង់ទឹកដែកចាស់មួយ រត់តាមបណ្តោយអគារភ្ជាប់ទៅអាងស្តុកទឹក (ពុំមានការប្រើប្រាស់ទៀតទេ) ដែលបច្ចុប្បន្នមានសភាពច្រេះពុកតាមកន្លែងមួយចំនួន បណ្តាលឲ្យទឹកធ្លាយចេញតាមបំពង់ និងហូរដក់លើផ្ទៃមួយចំនួននៃលេណគ្រឹះ ជាពិសេសនៅផ្នែកជ្រុងខាងកើត។ កត្តានេះបណ្តាលឲ្យស្រុតគ្រឹះមួយចំនួន ហើយជញ្ជាំងវិហារនៅជ្រុងខាងកើតទទួលរងនូវការប្រេះស្រាំផងដែរ។



*បំពង់ទឹកដែកឆ្លងកាត់ក្នុងលេណគ្រឹះ និងការខូចខាតពុកធ្លុះធ្លាយមួយចំនួន ដែលធ្វើឲ្យទឹកហូរចេញ*



*ស្ថានភាពទឹកដក់ក្នុងលេណគ្រឹះ ដោយសារការលេចធ្លាយពីបំពង់ទឹកចាស់*





*រូបភាពបង្ហាញពីស្ថានភាពធ្នឹមបេតុងលេណគ្រឹះមុនពេលជួសជុល*

## ខ. តួព្រះវិហារ

ជាទូទៅ តួព្រះវិហារមានស្ថានភាពនៅល្អរឹងមាំ ពុំមានអ្វីគួរឲ្យកត់សម្គាល់ឡើយ លើកលែងតែជញ្ជាំងនៅជ្រុងទិសឦសាន មានស្នាមប្រេះ ដោយសារការស្រុតនៃសំណង់គ្រឹះ ដូចបានបង្ហាញជូនខាងលើ។



*ស្ថានភាពតួសំណង់ព្រះវិហារ (ឆ្នាំ២០១០)*



រូបភាពមើលពីខាងកើត



រូបភាពមើលពីខាងត្បូង

www.phnompenh.gov.kh

## គ. ផ្នែកដំបូល

**<u>ស្ថានភាព:</u>**

- ជាទូទៅ គ្រឿងបង្គុំឈើនៃគ្រោងដំបូល មានស្ថានភាពនៅល្អ។
- នៅលើពិតានបាយអ មានកាកសំណល់បំណែកក្បឿងជាច្រើន និងធូលីពេញផ្ទៃទាំងមូល។

**<u>ដំណោះស្រាយ:</u>**

- សំអាតលើផ្ទៃពិតាន។
- ជួសជុលគ្រឿងបង្គុំឈើដែលខូចខាត និងលាបថ្នាំការពារសត្វកណ្ដៀរ។



រូបភាពពុះ ក ក



រូបភាពពុះ ខ ខ



*ទិដ្ឋភាពគ្រឿងបង្គុំឈើនៃគ្រោងដំបូល (ឆ្នាំ២០១០)*

## គ.១. ក្បឿង

__ស្ថានភាពៈ__

–ស្រទាប់ពណ៌រលោងនៅលើក្បឿង មានស្នាមប្រេះស្រាំជាច្រើន និងផ្ទាត់ពណ៌ចេញពីក្បឿង។

–ស្លែកាន់លើផ្ទៃក្បឿងក្លាយជាពណ៌ខ្មៅ។

–ក្បឿងមួយចំនួនបែកបាក់ និងមួយចំនួនទៀតទំនងជាជួសបំពេញថ្មី ដោយមានពណ៌ខុសពីក្បឿងចាស់។ កន្លែងខ្លះ បានជួសជុលបំពេញដោយស៊ីម៉ង់ត៍។

__ដំណោះស្រាយៈ__

–រុះរើក្បឿងចេញ ដោយយកក្បឿងដែលខូចខាតចេញ និងរក្សាក្បឿងដែលមានគុណភាពល្អទុកសម្រាប់ប្រក់ឡើងវិញ។

–វាយពាសស័ង្កសីលាតការពារទឹកនៅលើផ្ទោង និងបង្កង់ រួចវាយដែរណែងប្រក់ក្បឿងឡើងវិញ។



ក្បឿងមួយចំនួនបែកបាក់
និងស្រទាប់ពណ៌រលោងមានស្នាមប្រេះស្រាំផ្ដាច់ចេញពីក្បឿង





ស្នាមប្រេះព្រំប្រក់ក្បាលក្បឿង និងនាគជង់ក្តារពីស៊ីម៉ង់ត៍ (ឆ្នាំ២០១០)

## គ.២. ក្បាច់លម្អ (ជហ្វា នាគជងក្ការ នាគចែង ហោជាង អៃរ៉ា រូបគ្រុឌ កិន្នរ និងក្បាច់រងស្សរ)

**ស្ថានភាព៖**

- ជហ្វា នាគជងក្ការ និងនាគចែងមួយចំនួន មានស្នាមប្រេះស្រាំ។ក្បាច់រងស្សរធ្វើពីស៊ីម៉ង់ត៍ បំពាក់ដោយភ្ជាប់ជាមួយបង្កង់ឈើ។ បច្ចុប្បន្ន ភាគខាងចុងនៃបង្កង់ឈើទាំងនោះមានសភាពខូចខាតមួយចំនួនដែលធ្វើឲ្យក្បាច់រងស្សរត់មិនត្រង់គ្នា និងមួយចំនួនស្រុតចុះ។
- ក្បាច់លម្អភាគច្រើន រលុបបាត់ក្បាច់លំអិត ដោយការលាបថ្នាំពណ៌ជាន់គ្នាជាច្រើនស្រទាប់។

**ដំណោះស្រាយ៖**

- រុះរើក្បាច់លម្អ ដើម្បីពង្រឹងឡើងវិញ។ ផ្នែកដែលបែកបាក់ ត្រូវផ្លាស់ប្តូរថ្មី។
- ភ្ជាប់ជហ្វា នាគចែង បៃរកា រងស្សរ ។
- ឈូស កោស ខាត់ថ្នាំពណ៌ចាស់ចេញ និងលាបថ្នាំពណ៌ថ្មីឡើងវិញ។



*ស្ថានភាពក្បាច់រងស្សរ ដែលរំពើករំពើន រត់មិនត្រង់ផ្លូវគ្នា (ឆ្នាំ២០១០)*

## ២.២. ស្ថានភាព គំនូរ និង រូបចម្លាក់

### ក. ទិដ្ឋភាពទូទៅខាងក្នុងព្រះវិហារ

<u>ស្ថានភាព</u>៖

– ផ្សែងធូប និងទៀន ធ្វើឲ្យទិដ្ឋភាពខាងក្នុងព្រះវិហារមានសភាពអាប់អួ និងប៉ះពាល់យ៉ាងខ្លាំងដល់គុណភាពគំនូរ និងចម្លាក់។

– ចម្លាក់ពុទ្ធបដិមា តូចធំ ច្រើនស្អេកស្កះ គ្មានទីសម្រាប់ដើរទស្សនា និងសំអាត។



*ទិដ្ឋភាពខាងក្នុងព្រះវិហារ ដែលមានសភាពអាប់អួដោយសារផ្សែងធូប និងទៀន*

 

*ចម្លាក់ពុទ្ធបដិមា តូច-ធំ និងទូតាំងច្រើនស្អេកស្កះ គ្មានទីសម្រាប់ដើរទស្សនា និងសំអាត*

## ខ. គំនូរ (នៅលើជញ្ជាំង សសរ ពិតាន និងនៅលើទ្វារបង្អួច)

<u>**ស្ថានភាព៖**</u>

– គំនូរចែកជាពីរផ្នែក៖ ផ្នែកខាងលើ (ពិតាន) មានអាយុកាលចំណាស់។ គំនូរលើជញ្ជាំងជាគំនូរថ្មី ប្រហែលគូរឡើងវិញនៅចុងទសវត្សឆ្នាំ១៩៩០ ឬដើម២០០០។

– ផ្ទៃគំនូរទាំងមូលបានប្រែពណ៌ទៅជាខ្មៅស្រអាប់ ដោយសារផ្សែងធូប-ទៀន។

– គំនូរនៅលើពិតាន មានស្ថានភាពខូចខាតស្ទើរតែទាំងស្រុង ដោយកន្លែងខ្លះស្ទើរតែពុំនៅសេសសល់ស្លាកស្នាម។ កត្តានេះ បណ្តាលមកពីភាពចំណាស់ផងមកពីសំណើម និងទឹកជ្រាបពីដំបូលផង ព្រមទាំងពីផ្សែងធូបទៀនផង។

<u>**ដំណោះស្រាយ៖**</u>

– លាងសំអាត យកស្នាមប្រឡាក់ និងផ្សែងខ្មៅចេញពីផ្ទៃគំនូរ។

– ជួលជុលផ្ទៃជញ្ជាំង ទ្វារ និងបង្អួចឈើ ដែលខូចខាត ប្រេះស្រាំ និងលាងសំអាត។

– អភិរក្សគំនូរចាស់ និងពង្រឹងស្រទាប់គំនូរឲ្យរឹងមាំឡើងវិញ។

– ជួសជុលគំនូរដែលខូចខាត និងគូរឡើងវិញចំពោះរូបគំនូរបាត់រូបភាព។



*ទិដ្ឋភាពគំនូរ ដែលទទួលរងនូវការខូចខាតដោយសារ សំណើមទឹកជ្រាបពីដំបូល និងផ្សែងធូបទៀន*

## គ. រូបចម្លាក់ (ពុទ្ធបដិមា បល្ល័ង្ក និងបុស្បុក)

__ស្ថានភាព៖__

– ជាទូទៅ ពុទ្ធបដិមា និងបល្ល័ង្ក មានស្ថានភាពនៅល្អប្រសើរ ក៏ប៉ុន្តែផ្ទៃទាំងមូល មានសភាពខ្មៅស្រអាប់ ដោយផ្សែងធូបនិងទៀន។

__ដំណោះស្រាយ៖__

– លាងសំអាត យកស្នាមប្រឡាក់ និងផ្សែងខ្មៅ ចេញពីផ្ទៃរូបចម្លាក់។

– ជួលជុលផ្នែកគំនូរដែលខូចខាត ។



*ទិដ្ឋភាពរូបចម្លាក់ បល្ល័ង្ក និងបុស្បុក*

## ២.៣. ស្ថានភាព ជញ្ជាំង បង្កាន់ដៃ សសរ និងគ្រឿងបង្គុំឈើ

**ស្ថានភាព៖**

– ស្រទាប់ថ្នាំពណ៌នៅលើជញ្ជាំងមានកម្រាស់ក្រាស់លាបច្រើនដងជាន់ពីលើគ្នា។ ថ្នាំពណ៌នៅលើជញ្ជាំង និងនៅលើឈើ មានលក្ខណៈខុសពីពណ៌ដើម។

– ស្រទាប់ថ្នាំពណ៌មួយចំនួន បានប្រេះហើបចេញពីផ្ទៃជញ្ជាំង។

**ដំណោះស្រាយ៖**

– ជួសជុលជញ្ជាំង និងកែសម្រួលក្បាច់លម្អ ឲ្យសមទៅតាមលក្ខណៈទ្រង់ទ្រាយដើមវិញ។

– ឈូសកោសខាត់ ស្រទាប់ថ្នាំពណ៌នៅលើជញ្ជាំងចេញ រួចលាបថ្នាំពណ៌ថ្មី ។

– ផ្លាស់ប្តូរឈើដែលខូចខាត ឬពុកផុយចេញ និងពង្រឹងផ្នែកមួយចំនួន។

– ឈូសខាត់ថ្នាំពណ៌នៅលើឈើចេញ ដោយលាបថ្នាំការពារសត្វល្អិត។



*រូបភាពបង្ហាញពីការខូចខាតនៃស្រទាប់ថ្នាំពណ៌លើជញ្ជាំងខាងក្រៅ* (ឆ្នាំ២០១០)

## ២.៤. បណ្តាញអគ្គិសនី និងប្រព័ន្ធភ្លើងបំភ្លឺ

**ស្ថានភាព៖**

– បណ្តាញខ្សែអគ្គិសនីចាស់បានរាយនៅតាមគ្រោងឈើដំបូល និងតាមជញ្ជាំង ដោយពុំមានវិធានការការពារត្រឹមត្រូវ និងពុំមានសណ្តាប់ធ្នាប់ ធ្វើឲ្យប៉ះប៉ាល់សោភ័ណភាពព្រះវិហារ និងងាយប្រឈមនូវគ្រោះថ្នាក់អគ្គីភ័យ។

www.phnompenh.gov.kh

– អំពូលបំភ្លឺ បំពាក់នៅតាមសសរ ពុំមានពន្លឺគ្រប់គ្រាន់ និងធ្វើឲ្យប៉ះពាល់សោភ័ណភាពនៃទិដ្ឋភាព ខាងក្នុងព្រះវិហារ។

<u>ដំណោះស្រាយ៖</u>

– ដំឡើងទូចែកចាយអគ្គិសនីថ្មី។ បំពាក់ប្រអប់ភ្ជាប់ចរន្ត និងកុងតាក់ថ្មី។
– ប្តូរខ្សែភ្លើងចាស់ ដំឡើងខ្សែភ្លើងថ្មី ដោយមានស្រោមការពារត្រឹមត្រូវ។
– បំពាក់អំពូលភ្លើងថ្មី ស្របតាមលក្ខណៈបច្ចេកទេស និងសោភ័ណភាព។





*ស្ថានភាពខ្សែភ្លើងមកពីក្រៅចូលមកក្នុងព្រះវិហារ*



*អំពូលភ្លើងបំពាក់នៅតាមសសរ ពុំមានពន្លឺគ្រប់គ្រាន់ និងប៉ះពាល់ដល់សោភ័ណភាព*

# ៣. ការងារជួសជុល និងកែលម្អព្រះវិហារវត្តភ្នំ

## ៣.១. ពិធីក្រុងពាលីបើកការដ្ឋានជួសជុលកែលម្អព្រះវិហារវត្តភ្នំ

ដោយទទួលបានការឯកភាពដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម កែប ជុតិមា** អភិបាលរាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១០ សាលារាជធានីភ្នំពេញបានរៀបចំពិធីក្រុងពាលីនៅមុខបរិវេណព្រះវិហារវត្តភ្នំ ក្រោមអធិបតីភាពលោកជំទាវ **នួន សារ៉ុម** អភិបាលរងរាជធានីភ្នំពេញ តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមអភិបាលរាជធានីភ្នំពេញ** និងមានការចូលរួមពីថ្នាក់ដឹកនាំមន្ត្រីសាលារាជធានីភ្នំពេញ ក្រុមការងារសិលា មន្ត្រីមន្ទីរវប្បធម៌រាជធានី និងអ្នកសារពត៌មានជាច្រើនរូបទៀត។



*រូបភាពក្នុងឱកាសប្រារព្ធពិធីក្រុងពាលីនៅមុខបរិវេណព្រះវិហារវត្តភ្នំ ព្រឹកថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១០*

## ៣.២. ការងារពង្រឹង ជួសជុល និងកែលម្អ ផ្នែកសំណង់ព្រះវិហារៈ លេណគ្រឹះ ដំបូល ជញ្ជាំង ខឿន ទ្វារ បង្អួច

### ក. ការងារជួសជុលលេណគ្រឹះ




*ការសំអាតស្រទាប់បេតុងដែលខូចគុណភាព*




*ដែក និងបេតុងថ្មីក្រោយពេលលាងសំអាត*




*ការរើបំពង់ទឹកចាស់ចេញ*





ការពង្រាប និងបង្ហាប់ដីក្នុងលេណដ្ឋានគ្រឹះ





ការរៀបចំច្រកទ្វារចូលលេណដ្ឋានគ្រឹះឲ្យធំជាងមុន និងដាក់សន្លឹកទ្វារថ្មី



ទិដ្ឋភាពលេណដ្ឋានគ្រឹះក្រោយពេលជួសជុល

## ខ. ការងារជួសជុលផ្នែកដំបូល ជញ្ជាំង ទ្វារ និងបង្អួច



ការរុះរើក្បឿង និងដែរណែន





ការរុះរើក្បឿង និងដែរណែន

www.phnompenh.gov.kh





ការសំអាតពិតាន និងគ្រឿងដំបូល





ការលាបថ្នាំការពារកណ្ដៀរនៅលើគ្រឿងបង្គុំឈើនៃគ្រោងដំបូល





ការលាបម្រ័ក្សណ៍ការពារគ្រឿងឈើនៅជុំវិញល្វែងបាំងសាច









ការក្រាលសន្លឹកសំង្កសីពីក្រោមដៃរណែង







ការប្រក់ក្បឿងឡើងវិញទៅតាមទម្រង់ពណ៌ដើម



រងស្បូវចាស់បំពាក់ផ្ទាល់នឹងចុងផ្ដោង រត់មិនត្រង់ជួរ មានសភាពទ្រុឌទ្រោម និងបែកបាក់





ការបំពាក់រងស្បូវថ្មី ដោយភ្ជាប់លើបន្ទះក្តារ





ការបំពាក់សំណាញ់ក្រោមដំបូលការពារកុំឲ្យសត្វប្រចៀវចូលទៅខាងក្នុងដំបូល




ជហ្វាចាស់មានសភាពទ្រុឌទ្រោមបែកបាក់មួយចំនួន និងមួយចំនួនទៀតទ្រេតទៅឆ្វេង ឬទៅស្តាំ មិនត្រង់ជួរ និងការដំឡើងជហ្វាថ្មី




ការដុសខាត់សំអាតថ្នាំពណ៌ចាស់ដែលលាបជាន់គ្នាច្រើនស្រទាប់លើក្បាច់ហោជាង




ការជួសជុលពង្រឹងបៃរកា និងដំឡើងឲ្យរឹងមាំល្អឡើងវិញ





ការជុសខាត់រូបកិន្នរសំអាតយកថ្នាំពណ៌ចាស់ដែលលាបជាន់គ្នាច្រើនស្រទាប់





ការកោសខាត់ និងសំអាតថ្នាំពណ៌ចាស់លើខឿន និងជញ្ជាំងព្រះវិហារ









ការកោសខាត់ និងសំអាតថ្នាំពណ៌ចាស់លើខឿន និងជញ្ជាំងព្រះវិហារ





ការជួសជុលប៉ះបំពេញនៅផ្នែកពុកផុយ ខូចខាត និងប្រេះស្រាំ







ការបៀកថ្នាំជញ្ជាំង



ស្ថានភាពបង្អួច មុនធ្វើការជួសជុល



ការជួសជុល និងលាបទ្វារ-បង្អួច



ការសិក្សាថ្នាំពណ៌លើជញ្ជាំង



រូបភាពពណ៌លើជញ្ជាំងឆ្នាំ១៩៦២



រូបភាពសំណង់ព្រះវិហារក្រោយពេលជួសជុលរួច

## ៣.៣. ការងារពង្រឹង ជួសជុល និងលាងសំអាតគំនូរនៅលើៈ ជញ្ជាំង ពិតាន ទ្វារ បង្អួច និងសសរ

### ក. ការថតរូបគំនូរដើម្បីចងក្រងជាឯកសារ




ការថតរូបគំនូរដើម្បីចងក្រងជាឯកសារ




គំនូរលើជញ្ជាំង



គំនូរពិតានផ្នែកខាងលើ



គំនូរលើទ្វារ និងបង្អួច

## ខ. ការផ្ទួសផុល ពង្រឹង និងលាងសំអាតគំនូរ




ការពង្រឹងជញ្ជាំងប្រេះ និងផ្ទួសផុលគំនូរដែលខូចខាត









ការលាងសំអាតគំនូរលើជញ្ជាំង ពិតាន និងសសរ





សកម្មភាពលាងផ្សែងខ្មៅដែលគ្របលើគំនូរ





រូបភាពបង្ហាញពីសភាពគំនូរ (ផុះ របក ផ្កាត់ពណ៌) ក្រោយពេលលាងផ្សែងខ្មៅ





សកម្មភាពជួសប់ពេញផ្ទៃគំនូរដែលខូច





សកម្មភាពលាងសំអាត និងដកជាតិអំបិល ចេញពីផ្ទៃជញ្ជាំងគំនូរ



ការលាងសំអាតទ្វារផ្នែកខាងមុខ ផ្នែកខាងក្រោយ

## គ. ការប្រៀបធៀបរូបគំនូរ មុន និងក្រោយពេលជួសជុល















រូបភាពគំនូរនៅផ្នែកពិតាន មុនពេលជួសជុល



រូបភាពគំនូរនៅផ្នែកពិតាន ក្រោយពេលជួសជុល

## ៣.៤. ការងារពង្រឹង ជួសជុល និងលាងសំអាតរូបចម្លាក់៖ ព្រះអង្គធំ បុស្បុក និង ពុទ្ធបដិមា



*ការលាងសំអាតព្រះពុទ្ធរូប*



*ការលាងសំអាតបុស្បុក និងព្រះអង្គធំ*

## ៣.៥. ការងាររៀបចំបណ្តាញអគ្គិសនីថ្មី៖ បំពាក់ខ្សែភ្លើង ទូបញ្ជា អំពូលភ្លើង និងដំឡើងបង្គោលភ្លើង





ការរាយបណ្តាញខ្សែភ្លើងថ្មី





ការដំឡើងទូបញ្ជាភ្លើង និងរាយខ្សែភ្លើងក្នុងព្រះវិហារ



ការបំពាក់អំពូលភ្លើងក្នុងព្រះវិហារ



រូបភាពភ្លើងបំភ្លឺនៅអគារព្រះវិហារ

## ៣.៦. ការងារជួសជុលកែលម្អបរិវេណលើភ្នំ ដើម្បីសំរួលដល់ការទស្សនា

### ក. ការជួសជុលកម្រាលខឿន




*រូបភាពកំរាលការ៉ូផ្លូវដើរជុំវិញព្រះវិហារប្រេះ និងស្រទាប់បាយអក្រាលការ៉ូហើប និងជ្រាបទឹក ពុកផុយខូចគុណភាព (មុនពេលជួសជុល)*




*រូបភាពកំរាលការ៉ូជុំវិញព្រះវិហារ (ក្រោយពេលជួសជុលរួច )*

## ខ. ការជួសជុលជណ្តើរខាងជើងព្រះវិហារ




រូបភាពជណ្តើរខាងជើងព្រះវិហារ មុនពេលជួសជុល និងក្រោយពេលជួសជុលរួច




រូបភាពដងទង់ជាតិនៅពីមុខព្រះវិហារ មុនពេលជួសជុល និងក្រោយពេលជួសជុលរួច

## គ. ការជួសជុលជើងបង្គោលភ្លើង





រូបភាពកែលម្អជើងបង្គោលភ្លើង (១១ដើម) នៅជុំវិញបរិវេណលើភ្នំ

# ៤. លទ្ធផលសម្រេចនៃគម្រោងជួសជុលកែលម្អព្រះវិហារវត្តភ្នំ



រូបភាពព្រះវិហារវត្តភ្នំ មុនពេលជួសជុល



រូបភាពព្រះវិហារវត្តភ្នំ ក្រោយពេលជួសជុល



រូបភាពតំនូរក្នុងព្រះវិហារ មុនពេលជួសជុល



រូបភាពគំនូរក្នុងព្រះវិហារ ក្រោយពេលជួសជុល



រូបភាពបដិមា មុនពេលផ្លាស់ប្ដូរ



រូបភាពបដិមា ក្រោយពេលជួសជុល



រូបភាពលេណគ្រឹះព្រះវិហារ មុនពេលជួសជុល



រូបភាពលេណគ្រឹះព្រះវិហារ ក្រោយពេលជួសជុល



រូបភាពភ្លើងបំភ្លឺក្នុងព្រះវិហារ មុនពេលជួសជុល



រូបភាពភ្លើងបំភ្លឺក្នុងព្រះវិហារ ក្រោយពេលជួសជុល

# <u>ឯកសារពិគ្រោះ</u>

**១.** សាលារាជធានីភ្នំពេញ “ការអភិរក្សបេតិកភណ្ឌវប្បធម៌” ។

**២.** សាលារាជធានីភ្នំពេញ “អបអរសាទរកំណើត ៥៧៥ រាជធានីភ្នំពេញ”។

**៣.** លោក ផាន់ មករា, *ក្នុងរជ្ជកាលព្រះបាទពញាយ៉ាត* សារណាបញ្ចប់បរិញ្ញាបត្របុរាណវិទ្យា ឆ្នាំ២០០៦។

**៤.** លោក ឃិន សុខ, CHRONIQUES ROYALES AU CAMBODGE, EFEO, Paris 1988.

**៥.** George Coedès, LA FONDATION DE PHNOM PEN AU XV$^{e}$ SIÈCLE D’APRÈS LA CHRONIQUE CAMBODGE, BEFEO, Hanoi 1913.

**៦.** លោក វណ្ណ មូលីវណ្ណ, *បុរីខ្មែរសម័យទំនើប*, វិទ្យាស្ថានរ៉ៃយំ, ភ្នំពេញ ២០០៤។

SELA GROUP

No. 314, St. 247, Sangkat Boeng Salang, Khan Toul Kok, Phnom Penh
E-mail : Selagrp@gmail.com

www.phnompenh.gov.kh

www.phnompenh.gov.kh

៦៩ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក
ខណ្ឌដូនពេញ រាជធានីភ្នំពេញ
ទូរស័ព្ទ : (៨៥៥) ២៣ ៧២២ ០៥៤ , ៧២៤ ១២៦
ទូសារ : (៨៥៥) ២៣ ៧៤៦ ១៥៦

#69, Preah Monivong Blvd., Sangkat
Srah Chak, Khan Daun Penh, Phnom Penh
Tel : (855) 23 722 054, 724 126
Fix : (855) 23 724 156

Website : www.phnompenh.gov.kh